# សិក្ខាកាមកថា

សម័យនេះជាសម័យដែលជនជាតិខ្មែរភ្ញាក់គំនិត គិតស្វែងរកចំណេះឲ្យកូនចៅកាន់តែមានច្រើនឡើង ៗ ជាលំដាប់ នៅក្រុងភ្នំពេញសព្វថ្ងៃនេះមានចំនួនកុមារា កុមារីលើសបន្ទុកសាលា រកកន្លែងរៀនពុំបានក៏សឹងមានចំនួនច្រើន ដោយសាលារកកន្លែងអង្គុយគ្មាន ដូចមានសេចក្តីសាសព្ទក្នុងកាសែតនគរវត្តលេខ .... ខែសេបតមប្រ៊ី ឆ្នាំ ១៩៣៨ ។

ក្នុងកាសែតប្រមូលសារចុះថ្ងៃទី ៣ ខែឲកតូប្រ៊ី ១៩៣៨ ដែលព្រះរាជបណ្ណាល័យបានទទួលនោះ មានសេចក្តីនិយាយអំពីការសិក្សាថា:

តាមដោយសេចក្តីពិត មនុស្សចាប់ផ្តើមការរៀនសូត្រតាំងអំពីថ្ងៃកើតមក ដូចយើងបានឃើញទារកដែលចេះសំឡឹងមើលមុខម្តាយរបស់ខ្លួន ដើម្បីរៀនមើលលក្ខណៈមុខមាត់ម្តាយរបស់ខ្លួន ដែលជាអ្នកបីបាច់ព្យាបាលឲ្យទឹកដោះខ្លួនបៅជាដើម ។ មួយវិញទៀត ប្រសិនបើយើងពិនិត្យមើលក្នុងខ្លួនមនុស្សយើងក៏គង់ឃើញច្បាស់ថា មនុស្សយើងមានចិត្តជាគ្រឿងដឹងមានប្រសាទទាំង ៥ ជាគ្រឿងប្រាប់ ប្រសាទប្រាប់មកយ៉ាងណា ចិត្តក៏ដឹងយ៉ាងនោះដែរ ប្រសិនបើចិត្តត្រូវការចង់ដឹងឲ្យច្រើនជាងនេះ ក៏ប្រើប្រសាទពិនិត្យត្រួតត្រាតទៅទៀត ឬយកចំណេះដែលបានមកតាមផ្លូវប្រសាទ ( សេចក្តីចាំ ) មកញែកវែកមើលឲ្យជាក់លាក់តទៅទៀត ដែលជាផ្លូវរកចំណេះបានមួយផ្លូវទៀតដែរ ។

ដែលពោលមកនេះល្មមយល់ថា ផលនៃការសិក្សា គឺសេចក្តីចេះដឹង ឯចំណេះចេះដឹងរបស់មនុស្សយើងនេះអ្នកប្រាជ្ញបារាំងចិត្តវិទ្យាពោលថា ជាវិស័យរបស់មនុស្សយើងដែលមាននៅតាមប្រក្រតីធម្មតា តែការចង់ចេះចង់ដឹងនេះមានមិនស្មើគ្នា គឺអ្នកខ្លះចង់ចេះចង់ដឹងមានកំឡាំងទន់ខ្សោយ អ្នកខ្លះមានការចង់ចេះចង់ដឹងយ៉ាងខ្លាំងក្លា ។ ពោលចំពោះមនុស្សដែលចង់ចេះចង់ដឹងយ៉ាងខ្លាំងក្លាប៉ុណ្ណោះ ដែលបានឈ្មោះថា ជាមេសិក្សាមែន ៗ ពួកមេសិក្សាមែន ៗ នេះឯង ជាអ្នកធ្វើគុណប្រយោជន៍យ៉ាងធំក្រៃលែងដល់លោក ត្រាតែលោកសន្មតនាមថាជាមហាបុរសឬបុរសរត្នក្នុងលោកនេះ ។

ដូចជាមានមនុស្សរាប់ជាចំនួនលាន បានឃើញផ្លែឈើទុំនៅលើដើមហើយជ្រុះចុះមកដល់ដី ក៏យល់ត្រឹមតែផ្លែឈើដែលជ្រុះពីមែកមកដល់ដីប៉ុណ្ណោះ ហើយក៏ហួសទៅ គឺស្រេចត្រឹមប៉ុណ្ណឹង មិនគិតស្រាវជ្រាវរាវរកហេតុហេតុផលអ្វីទៀត ចំណែកឯលោកសឺរអៃសែកនិវតាន់មិនមែនដូច្នោះទេ កាលបើលោកបានឃើញហើយ ក៏ចង់ចេះចង់ដឹងតទៅទៀតថា ចុះហេតុអ្វីទៀប

ផ្លែឈើជ្រុះ ? លោកនេះខំប្រឹងសិក្សាជាច្រើនឆ្នាំទើបបានដឹងហើយបានចំណេះបន្តិចតទៅទៀត អំពីច្បាប់ឬគំនិតនៃការយឹតយោងរបស់លោក នឹងច្បាប់ឬគំនិតនៃការវិលប្រទក្សិណនៃដួងផ្កាយ ។

ដូចជាបុគ្គលសំខាន់ ៗ នេះមានចំនួនច្រើន តែបុគ្គលដែលសំខាន់ជាន់ឯកនោះ គួរពោលចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដ្បិតកាលមុនស្តេចចេញទ្រង់ព្រះផ្នួស ទ្រង់បានទតឃើញមនុស្សកើត – មនុស្សស្លាប់ហើយទ្រង់មានព្រះបំណងចង់ជ្រាបថា មនុស្សគឺអ្វី ? ហេតុអ្វីបានជាមានកើតមានស្លាប់ ? ដោយទ្រង់មានព្រះបំណងយ៉ាងខ្លាំងអំពីហេតុនេះ ទើបព្រះអង្គទ្រង់លះបង់សុខសម្បត្តិស្រិង្គារដែលយើងរាល់គ្នាតែងជាប់ចិត្តរប់អានណាស់នេះចោលចេញហើយទ្រង់ព្រះផ្នួស ស្តេចត្រេចចារិកទៅកាន់សំណាក់គ្រូអាចារ្យដែលមានឈ្មោះល្បីល្បាញក្នុងសម័យនោះ ទ្រង់ព្យាយាមសិក្សាគ្រប់ ៗ សំណាក់ហើយ មិនបានសម្រេចដូចព្រះបំណង ហើយទ្រង់ល្បងរិះរកដោយព្រះអង្គឯងគ្រប់វិធី ក្នុងទីបំផុតទើបបានចួបប្រទះនឹងសេចក្តីពិតដែលហៅថាព្រះអង្គបានត្រាស់ គឺទ្រង់ជ្រាបសេចក្តីពិតថាមនុស្សគឺអ្វី ? ហើយទ្រង់ព្រះតម្រិះតទៅទៀតថា ត្រូវធ្វើដូចម្តេចទើបបានដល់បរមសុខដែលហៅថានិព្វានបាន ប៉ុន្តែយើងរាល់គ្នាមិនអាចដឹងដល់កន្លែងនេះទេ ព្រោះមិនអាចនឹងធ្វើសេចក្តីចូលចិត្តបានថា ព្រះនិព្វាននេះមានឱជារសវិសេសជាងស្ថានសួគ៌ដូចម្តេច ដ្បិតក្នុងស្ថានសួគ៌មានសេចក្តីដំណាលថា មាននាងទេពអប្សររូបរាងឆើត ៗ សុទ្ធតែក្រមុំ ៗ ដូចជាក្រមុំព្រហ្មចារីយ៍រាប់រយពាន់នៅចាំបំរើ ប្រគំនូវតូរ្យតន្ត្រីទិព្វគ្រប់ទិនទិវារាត្រី មានអាហារដ៏ឆ្ងាញ់ពិសាទុកជូនបរិភោគមិនចេះខ្វះខាត មិនព្រួយធ្វើការនឿយហត់រហូតដល់ស្លាប់ ។ ចំណែកព្រះនិព្វានមិនមានពោលដូច្នោះឡើយ ទុកជាដូច្នោះក៏ដោយ យើងជាពុទ្ធសាសនិកជននៅតែនាំគ្នាប្រាថ្នាសុំឲ្យសម្រេចដល់ព្រះនិព្វានជាដរាប ទើបឃើញថាមុខគួរតែពិចារណាពិនិត្យរកហេតុផលខ្លះចុះថា និព្វានគឺអ្វី ? ប្រសិនបើយើងគិតមើលសើ ៗ ត្រឹមសំបកក្រៅ គង់ឃើញថា នាងទេពអប្សរក្តី អាហារទិពក្តី គ្រឿងប្រើប្រាស់ដទៃ ក្នុងស្ថានសួគ៌នេះក្តី អស់នេះសុទ្ធតែជាគ្រឿងឧបករណ៍ដល់រាងកាយជាសេចក្តីត្រូវការរបស់រាងកាយ កាលបើគិតមើលពីរាងកាយនឹងឃើញថា រាងកាយនេះគ្រាន់តែជាវត្ថុអ្វីមួយ កាលបើដល់ពេលកើតក៏កើតឡើង ដល់ពេលវិនាសក៏វិនាសទៅ ដូចជាផ្លែឈើដែលកើតឡើង កាលដល់រដូវត្រូវជ្រុះរមែងជ្រុះពីដើមទៅជាធម្មតា កាលយើងពិនិត្យមើលទំនងនេះ ក្រែងអាចសំឡឹងទៅកាន់ព្រះនិព្វាននេះបានខ្លះដឹង ? ព្រោះថាបើយើងអាចជំរះចិត្តឲ្យភ្លឺច្បាស់ជ្រះស្រឡះបាន

ហើយ សេចក្តីយល់ដល់ខ្លួន គឺឃើញតែប្រយោជន៍ខ្លួន គង់នឹងសន្សឹម ៗ រសាយចេញពីចិត្ត បន្តិច ៗ ទៅ ហើយមានចិត្តមេត្តាករុណា នឹងយល់ដល់ចិត្តនៃគ្នានឹងគ្នាជាមិនខាន មនុស្សយើង បើជួយទុក្ខធុរៈទៅវិញទៅមក មិនមានអ្នកណាគិតព្យាបាទគ្នាទៅវិញទៅមកទេ សង្គ្រាមគង់តែ មិនមានកើតឡើង លោកនេះនឹងពោរពេញដោយសន្តិភាព ។

ការបានសម្រេចរបស់ព្រះពុទ្ធជាម្ចាស់ក្តី របស់សឺរអៃសែកនិវតាន់ក្តីរបស់បុគ្គលសំខាន់ ៗ ដទៃទៀតក្តី សុទ្ធតែមានមូលមកអំពីចតុប្រសាទកាលបើឃើញហើយមិនបណ្តោយឲ្យហួសទៅ ដូចជាមនុស្សសាមញ្ញទេ ទើបធ្វើឲ្យយើងសង្កេតបានថា បុគ្គលសំខាន់ ៗ នោះ សុទ្ធតែមនុស្សមេរៀន – មេគិត កាលបើមានវត្ថុអ្វីមកប៉ះចំពប់នឹងភ្នែករមែងកើតសេចក្តីបំណងចង់ចេះដឹងយ៉ាង ខ្លាំងក្លា ពិចារណាពរកហេតុផលដោយវិរិយៈ ឧស្សាហៈដ៏មាំមួន ទើបបានសម្រេចឥដ្ឋផល សមតាមបំណងគ្រប់ប្រការ ។

ខេមររង្សី